# រឿងស្នេហាមួយជាងមួយរយឆ្នាំមុន

«....យី បទភ្លេងបុរាណនេះដូចជាធ្លាប់ឮ? ប៉ុន្តែមនុស្សច្រើនម្ល៉េះ ធ្វើម៉េចបានចូលមើលទៅ?»

«ចង់មើលមែន?»

«ចង់!!!»

«អូខេ!»

«អូខេមានន័យថាម៉េច?»

សុភាពបុរសញញឹមធ្វើឱ្យចេន្នី ធ្វើមុខងឿងឆ្ងល់ចំពោះស្នាមញញឹមអាថ៌កំបាំង។ នាងក៏សួរបញ្ជាក់៖

«មង្គលឯង យកខ្ញុំចូលមើលបានមែន?»

«បានព្រះនាង ចាំមហាសេនារកមធ្យោបាយ!»

«អ្នកណាជាមហាសេនា? ខ្លួនហ្នឹង?» នាងសួរចំអកដោយញញឹមញញញែម។

«ឮសូរថា....មានមហាសេនាមែនកាលពីជំនាន់មុនៗ»

មង្គលនិយាយតប៖

«មាឌធំៗ» គេបញ្ជាក់ទៀត

នាងក៏សួរភ្លាម៖

«សម្រាប់អីទៅ?»

«សម្រាប់ការពារព្រះនាង! ប៉ុណ្ណឹងឆ្ងល់ដែរ!»

មង្គលជាបុរសសង្ហា កម្ពស់ប្រមាណជាមួយម៉ែត្រចិតសិបជាង។ គេទាញដៃចេន្នី មនុស្សស្រីក្រមុំកម្ពស់ប្រមាណជាមួយម៉ែត្រហុកសិប តូចស្ដើង ស្លៀកសំពត់ខ្លីកំបិតពាក់ស្បែកជើងប៉ាតា ចងសក់ញែកជាពីរដូចកូនក្មេងរៀនថ្នាក់អនុវិទ្យាល័យ ប៉ុន្តែតាមការពិត គេទាំងពីរបានបញ្ចប់មហាវិទ្យាល័យទៅហើយ។

ចេន្នីចូលចិត្តភ្លេងបុរាណៗណាស់ ឱ្យតែមានលក្ខណៈដូចចិនទៀតកាន់តែល្អ ប៉ុន្តែសំឡេងឧបករណ៍មួយនេះ មិនដឹងថា ចិន ឡាវ ឬក៏ខ្មែរនៅឡើយ។

«ប៉ុន្តែ....មង្គល! ភ្លេងហ្នឹងពីរោះលន្លង់លន្លោចពេកហើយ! យើង....យើងមានអារម្មណ៍ថា ធ្លាប់ស្គាល់ ធ្លាប់បានស្ដាប់មកតាំងពីសម័យកាលណាមិនដឹងទេ»

ខាងប្រុសមិនឆ្លើយ ព្រោះភ្លាមនោះ គេញែកហ្វូងមនុស្សបានសម្រេច សម្លឹងជំទើតមើលទៅក្រុមអ្នកប្រគំតន្ត្រី ដើម្បីរែអង្គាសប្រាក់។

ភ្លាមៗ ចេន្នីដែលកំពុងចាប់ភ្លឹកនឹងភ្លេង បែរជាក្រឡេកមកចែដន្យ ចាប់អារម្មណ៍ឃើញថា សង្សារជាប់ភ្នែកមើលទៅលើមនុស្សស្រីសក់វែងត្រឹមចង្កេះដែលកំពុងតែឈ្ងោកដេញពិនបញ្ឈរមួយ។

ចេន្នីងាក តែមនុស្សស្រីនោះ បើពិនិត្យពិច័យឃើញមានព្យួរផ្កាចំប៉ាព្រៃវែងៗពីបីទងលើសរសៃសក់។ នាងទម្លាក់សក់គ្របមុខមួយចំហៀង បញ្ចេញថ្ពាល់វែង និងទម្រង់មុខថ្គាមខ្លាមានខួចទាំងមិនបានសើច។

ដោយសារនាងនោះមានចិញ្ចើមក្រាស់ៗ រោមភ្នែកខ្មៅវែង ទោះស្រីអ្នកលេងពិណមិនបានងើបមុខឡើងមក ប៉ុន្តែស្រស់ផូរផង់ពេកណាស់។

ជាមួយសម្បុរស្រអែម រាងតូចទ្រនាប់ ម្រាមដៃវែងៗ អ្នកលេងពិណត្រូវបានមង្គលជាប់ភ្នែក។

ចេន្នីមានអារម្មណ៍អត់សប្បាយចិត្តពេលឃើញនារីអ្នកលេងភ្លេងបុរាណម្នាក់នេះ។

«អស់អារម្មណ៍ស្ដាប់រលីង!» ចេន្នីគិតក្នុងចិត្ត។

មើលមកម្ដងណាឃើញតែមង្គលសើចញញឹមចេញធ្មេញ២ជួរទាំងខាងលើនិងក្រោមយ៉ាងពេញចិត្តចំពោះស្រីដែលលេងពិណ។

ងាកទៅគ្រប់គ្នា អ្នកណាក៏សម្លឹងទៅមនុស្សស្រីលេងភ្លេងមិនញញឹមម្នាក់នោះ ដូចនាងមានមន្តសណ្ដំទស្សនិកជនពេកពិត។

«តោះ»

កន្ត្រាក់ដៃមង្គលចេញប្រធាប់ប្រភីង ធ្វើឱ្យសង្សារមិងមាំងងាកមក។ ចេន្នីខាំមាត់គ្រឹតហើយក្តិចដៃនាយ៖

«គ្មានអីល្អមើលផង! ត្រលប់ទៅផ្ទះវិញ!»

ពីរខែក្រោយ.....ជាពេលាដែលភ្លេងការមកប្រគំនៅខាងក្រៅផ្ទះចេន្នី។ នេះជាថ្ងៃរៀបការពិតមែនដែលនាងរង់ចាំយូរណាស់មកហើយ។

ក្នុងបន្ទប់កូនក្រមុំ ម្ដាយនាងឧទានឡើងដដែលៗ៖

«ស្អាតណាស់កូនស្រីខ្ញុំ!»

ចេន្នីសម្លឹងខ្លួនឯងក្នុងកញ្ចក់ ហើយញញឹមចំពោះជោគវាសនា ខណៈមិនយូរប៉ុន្មានម្ដាយរបស់នាងបានយកគ្រឿងអលង្ការមួយប្រអប់មកបង្ហាញ។

«ជាស្អីទៅម៉ាក់?»

«ជាកេររបស់លោកយាយ»

នាងសម្លឹងទៅខ្សែកបុរាណយ៉ាងធំ បារម្ភខ្លាំងណាស់អាចថាមិនសមនឹងសម័យនេះ។

«បុរាណពេកដឹងម៉ាក់?

«ប៉ុន្តែសមជាមួយពិធីមង្គលការ!»

«អូខេ»

«អូអត់ទេ!» ម៉ាក់បន្តនិយាយពេលពាក់ឱ្យនាង៖

«តទៅត្រូវពាក់ មិនមែនត្រឹមតែសម្រាប់ពិធីមង្គលការទេ គឺរហូតតទៅកូន!»

ចេន្នីនៅស្ងៀម ខណៈពេលគិតថា ឱ្យតែម្ដាយមិននៅនឹងដោះទុក។ នាងសម្លឹងទៅម្ដាយកំពុងដាក់គន្លឹះឱ្យ ប្រភេទខ្សែកអីក៏មិនដឹង ធ្វើអំពីប្រាក់ឬក៏អ្វី មានពណ៌ស មានត្បូងគ្រប់ពណ៌ សក្តិសមនឹងពិធីនេះនិងអាវបុរាណនេះ ប៉ុន្តែម៉េចនឹងអាចពាក់ជារៀងរាល់ថ្ងៃទៅ។

នាងគិត ឯម្ដាយបន្តនិយាយបង្គាប់៖

«ជារបស់បុរាណស័ក្តិសិទ្ធសម្រាប់ការពារ! និងនាំមកនូវសេចក្ដីចុំចើ្រង! កុំឱ្យធ្លាក់ដល់ដៃអ្នកណាឱ្យសោះណ៎!»

«ចាំម៉ាក់»

ចេន្នីខ្ជិលតវ៉ាច្រើន ដោយសារពេលនេះហាក់ក្លឹកត្រចៀកទៅនឹងសំឡេងអ្វីម្យ៉ាងពីរោងការខាងក្រោមផ្ទះ។

ភ្លេងអីគេនឹងម៉ាក់?

«ភ្លេងខ្មែរហ្នឹង!» ម្ដាយតបហាក់បីដូចជាមិនចាប់អារម្មណ៍។ លុះឃើញនាងផ្ទៀងស្ដាប់មិនលែងក៏តឿន៖

«ភ្លេងការហ្នឹងណាកូន!» ថាហើយគាត់អាល័យតែភ្លឹកញញឹមពេញចិត្តមើលខ្សែក ប៉ុន្តែចេន្នីមានអារម្មណ៍មិនសូវសប្បាយចិត្តជាខ្លាំង ដូចជារកនឹកឃើញថាភ្លេងដ៏ស្រងេះស្រងោចនេះមិនសមជាមួយមង្គលការរបស់នាងថ្ងៃនេះនោះទេ។ ម្ដាយនាងចេញបាត់ទុកនាងឱ្យក្រុមតុបតែងផ្ទង។

«ឈប់ៗ» នាងរុញដៃជើងផ្ទួងដែលកំពុងចងសក់ ហើយពាក់ខ្សែកបុរាណធំដើរចេញទៅក្រៅឈ្មោកពីលើរានហាលខាងមុខបន្ទប់មួយនេះ សម្លឹងទៅក្រោម។ យ៉ាងណាក៏មើលមិនឃើញក្រុមភ្លេងនោះទេ ប៉ុន្តែពិតជាឮសំឡេងភ្លេងនេះ....

«ឱ នឹកឃើញហើយ! ភ្លេងមួយនេះ ពិណនេះដេញដោយមនុស្សស្រីសក់វែងចងផ្កាចំប៉ា!»

មានអារម្មណ៍អត់សប្បាយចិត្ត។ គិតថា មិនដឹងជាបទជនជាតិអ្វី ប៉ុន្តែដូចជាមានអ្វីមិនដឹង ប្លែកៗ ហាក់បីជាអារក្សឬមន្តអូមអាមស្អីមួយ។

«បងមង្គលលង់មើលគេឡើងចំហមាត់ញញឹមចេញធ្មេញទាំងជួរ!» នាងនិយាយម្នាក់ឯងដូចត្រូវសណ្ដំ

«និយាយស្អីនឹងនរណាហ្នឹងកូន? គ្មានអ្នកណានៅរានហាលនេះទេ!»

មិននឹកស្មានថា លបភ្លាត់មាត់រវើរវាយនិយាយរឿងចាស់ខ្សឹបៗ ក៏ត្រូវម្ដាយមកដល់ទាន់និងស្ដាប់ឮសោះទេ។

កូនក្រមុំរុញម្ដាយចូលក្នុងផ្ទះវិញដោយស្នើសុំ៖

«ម៉ាក់ ភ្លេងនេះកម្សត់ណាស់កុំឱ្យគេលេងទៀត!»

ម្ដាយផ្ទៀងស្ដាប់។

«តែ....បទភ្លេងការធម្មតាសោះហ្នឹងកូន!»

«ធម្មតាទៀត? ស្ដាប់មើលទៅម៉ាក់ មិនដែលការអ្នកណាគេលេងបទចឹងទេ!»

ពេលម្ដាយស្ដាប់ទៀតក៏ចេន្ទីខ្លួនឯងយល់ថា ពេលនេះផ្ទង់ស្ដាប់ទៅ ហាក់មិនមែនបទមួយដែលនាងឮមុននេះទៀតនោះទេ គឺជាបទភ្លេងការធម្មតាពិតមែន។

ថ្លោះទឹកមុខ ចេន្ទីមានអារម្មណ៍មិនសូវសប្បាយចិត្តសោះ តែម្ដាយមិនចាប់អារម្មណ៍ច្រើនរវល់តែសប្បាយចិត្ត។

«មក! កុំឱ្យខាតពេលកូន ជិតដល់ម៉ោងក្រុងពាលីហើយ!»

ពេលអូសកូនចូលស្លៀកក្បិន គាត់ប្រាប់ទៀតថា៖

«មួយទៀតកូននី! យប់នេះចូលគេងឆាប់ ហាមលេងទូរសព្ទឬផុសនេះនោះជក់ភ្លេចខ្លួននាំតែរូងភ្នែកស្លក់អស់! ព្រោះស្អែកជាថ្ងៃមង្គលរបស់កូន មានតែម្ដងក្នុងឆាកជីវិត! ឱ្យទូរសព្ទមក ម៉ាក់សុំទុកឱ្យសិន!»

ចេនីហុចទៅឱ្យគាត់ ហើយព្យាយាមទម្លាក់ចោលភាពសៅហ្មង ប៉ុន្តែវានៅតែមានអ្វីមួយជាប់ក្នុងទ្រូងស្អិតៗ ស្ងាត់ៗ មិនដឹងហេតុផលច្បាស់។

ទោះបីជានាងបានតែងខ្លួនស្លៀកក្បិនយ៉ាងសង្ហាជាមួយនឹងខ្សែកកេររបស់លោកយាយដែលនាងទើបតែបានឃើញ នាងមិនបានញញឹមស្រស់ទេទាំងក្នុងនិងក្រោយកម្មវិធី។

របហូតម៉ោងពីរភ្លឺរាត្រីនោះ នាងក្រោកបើកទូទឹកកកចាក់ទឹកព្រោះគេងយ៉ាងណាក៏មិនលក់។

ស្រមោលមួយអណ្តែតរសាត់ស្រាលស្ទើកមកពីក្រោយ សឹងថាលោះព្រលឹងអស់ហើយ នាងងាកក្រោយមកភ្ញាក់ព្រើតព្រោះឃើញរាងឈរផ្ទឹង កែវរបូតខ្វាយធ្លាក់ដល់ដី។

«ហើយ ភ្ញាក់អីដល់ថ្នាក់ហ្នឹងកូនម៉ាក់?»

«នៅសុខៗមកឈរពីក្រោយខ្ញុំធ្វើអីកណ្តាលអធ្រាត្រ»

«ព្រោះឆ្ងល់កូនម៉ាក់មិនទាន់គេង? ម៉េចអ៊ីចឹង? តែបន្តិចទៀតហ្នឹងអ្នកភ្នួងគេមកដល់ហើយ!»

«ខ្ញុំបានគេងខ្លះហើយម៉ាក់!» នាងរំអួយទឹកមុខធុញថប់ចម្លែក។ ម្តាយមិនយល់ទេ នេះមិនមែនជាអាពាហ៍ពិពាហ៍រៀបចំឯណា? មង្គលនិងចេន្នីស្រលាញ់គ្នាដោយចិត្ត។

«គិតរឿងអីខ្លះកូន?»

«មានហ្ន៎ា ក្រោកមកវិញ គេងលែងលក់តែម្តងម៉ាក់!»

«មុខមិនស្រស់សោះកូនក្រមុំនេះ!»

«មិនដឹងយ៉ាងម៉េចទេ ស្រាប់តែមានអារម្មណ៍មិនសូវល្អ!»

ម្តាយប្រញាប់ខ្សឹបឃាត់៖

«កុំនិយាយៗ! ត្រូវនិយាយថា មានអារម្មណ៍ល្អ ព្រោះថាជាថ្ងៃមង្គលណ៎ាកូន! តោះម្តាយទៅគេងក្បែរ! តែមួយម៉ោងទៀតភ្នួងនឹងមកដល់ហើយ!»

«ចាំ!»

បានម្តាយមកដល់ គាត់ប្រះគេងលើគ្រែក្បែរ ចេនីដើរទៅទាញបង្អួចបិទស្រាប់តែឃើញអ្វីម៉្យាងនៅខាងក្រោមផ្ទះ។

នាងលើកដៃខ្ទប់មាត់មិនចង់ស្រែកឮដល់ម្តាយទេ តែច្បាស់ទែងគឺមនុស្សស្រីសក់វែងមានចងផ្កាចំប៉ានោះកំពុងតែឈរនៅក្នុងសួនខាងក្រោមទាំងកណ្តាលរាត្រី ថែមទាំងងើយមើលមកបន្ទប់នេះ។

«ស្អីគេហ្នឹង?»

ទោះនាងនិយាយខ្សឹបៗប៉ុន្តែម្ដាយនាងបើកភ្នែកមកវិញព្រ ហើយភ្លាមនោះនាងមិនបានចាប់អារម្មណ៍ជាមួយម្ដាយទេព្រោះជាប់ភ្នែកជាមួយនឹងមនុស្សស្រីចម្លែកដែលលេងភ្លេងស្រងេះស្រងោច ។

ចាំ បានហើយ!

«មនុស្សស្រីម្នាក់នេះនៅបាត់ដំបងដែលកូនបានទៅថតPre-weddingខែមុន!»

«នៅឯណា?» ម្ដាយនិយាយសួរ ប៉ុន្តែគាត់នៅគេងលក់រលីវ មិនចង់ក្រោកតាមរបៀបស្ពឹករបស់មនុស្សងងុយ។ ស្រាប់តែចេន្ទីមិនអាចឆ្លើយ អណ្ដាតនាងត្រូវគាំងព្រោះឃើញរូបរាងគូដណ្ដឹងរបស់ខ្លួនដែលត្រូវជាកូនកំលោះនៅព្រឹកស្អែក កំពុងដើរមកដោយមុខញញឹមញញែមដាក់នារីនោះ រួចដឹកដៃស្រីសក់វែងចាកចេញទៅដោយបែរខ្នង។

ស្អីគេ?

ម្ដងនេះចេន្ទីស្រែកឡើងទាំងហួសចិត្តចង់ឱ្យម្ដាយនាងភ្ញាក់មកមើលភ្លាមៗ។ មិនមែនជាសប្តិទេ នាងញីភ្នែក។

ម្ដាយចាប់បានសម្លឹងស្លន់របស់ចេន្ទីពិតជាក្រោកមកមែន តែម្ដងនេះចេន្ទីមិនរវល់ជាមួយអ្នកម្ដាយទៀតនោះទេ នាងស្ទុះទៅរកទ្វារបន្ទប់យ៉ាងបន្ទាន់ទាំងរ៉ូបគេងយប់ ហើយរត់តាមជណ្ដើរចុះទៅជាន់ខាងក្រោមផ្ទះ។

«ទៅណាចេន្ទី?!»

ម្ដាយមកតាមពីក្រោយទាំងសង្ស័យលើផ្លូវចិត្តរបស់នាង។

ផ្ទះចេន្ទីនេះជាសំណង់ថ្មក្រោមឈើលើ។ នាងជាកូនស្រីទោលនៃគ្រួសារដែលមានជីវភាពមធ្យម ។ ជាកូនស្រីតែមួយម្នាក់នេះត្រូវបានមង្គលតាមស្រលាញ់ទំយើចិត្តជាយូរណាស់មកហើយ ទម្រាំបានយល់ចិត្តគ្នាហើយនាំចាស់ៗមកត្រូវគ្នារហូតដល់លេចចេញជាថ្ងៃសិរីនេះឡើង។

កាលពីខែមុនអ្នកទាំងពីរបានទៅសម្រាកនៅសណ្ឋាគារមួយដែលជាកន្លែងពួកគេរៀបចំស្នាក់សម្រាប់ថតព្រីវីឌីង ដោយមានទាំងម្ដាយខាងនាងនិងម្ដាយខាងគេទៅដែរ ប៉ុន្តែពេលនាងទៅផ្សារណាត់លេងនៅពេលយប់ជាមួយមង្គល ឃើញគេជុំគ្នាមើលភ្លេងបុរាណដែលលេងកំដរភ្ញៀវបរទេសសុំជំនួយសប្បុរសធម៌ក៏ចូលមើល។

មិននឹកស្មានថាថ្ងៃនេះ មនុស្សស្រីដែលធ្វើឱ្យបេះដូងចេន្ទីមានមន្ទិលយ៉ាងចម្លែកលាយឡំសេចក្ដី

បារម្ភ ទីបំផុតបានមកបង្ហាញខ្លួននៅក្រោមផ្ទះនេះ?

នាងបើកទ្វារយ៉ាងរហ័សខណៈគ្រប់គ្នាកំពុងគេងលក់ស្កាត់។

ប៉ុន្តែម៉ោងទៀបភ្លឺហើយ ហេតុអីបានជាមានឃើញស្រីម្នាក់នោះនៅខាងក្រៅផ្ទះ? នាងមកពីណាទៅណាមិនដេកពួនទេ?

ហើយបន្ទាប់មកឃើញអនាគតស្វាមីរបស់ខ្លួនដែលនឹងរៀបការនៅព្រឹកស្អែកកាន់ដៃនាងដើរទៅទៀត?

«បងមង្គលៗ»

គ្មានឃើញស្រមោលស្រីស្រស់សក់វែង ឬមួយក៏អនាគតស្វាមីអីទាំងអស់។

ស្ងាត់ច្រៀបមានតែសព្ទក្អកក្អាត់យំ ស្រាប់តែម្ដាយរត់មកតាមពីក្រោយ រួចចាស់ៗក្នុងផ្ទះក្រោកមកបើកទ្វារ ចេញអើតមើលតាមបន្ទប់នីមួយៗជាបន្តបន្ទាប់។

ចេន្ទីត្រហេបត្រហបប្រាប់ម្ដាយ៖

«ម៉ាក! ម៉ាក់! ខ្ញុំឃើញ ឃើញ ឃើញបងមង្គល.....!»

«ស្អីគេកូន?»

នាងរកនិយាយសឹងមិនបន្ទាន់ផងស្រាប់តែភ្លឺហ្វាឡានលូនមកដល់ខាងក្រៅផ្ទះ។ ចាស់អើតមើលខ្លះរត់ទៅបើកទ្វាររបង។ ម្ដាយរបស់ចេន្ទីក៏អាចមើលស្គាល់ដែរ គាត់លាន់មាត់ប្រាប់៖

«ឡានកូនកំលោះ មកដល់ហើយ!»

ចេន្ទីសឹងតែភ្លេចដកដង្ហើម ព្រោះឃើញគ្រួសារខាងប្រុសចតឡានប្រញិបប្រញាប់ រួចលេចឪពុកម្ដាយក្មេកនាងចុះមក ជាមួយនឹងប្អូនស្រីរបស់មង្គលផងដែរ។

«ឆាប់ឡើងមកពីងងឹតមែនអ្នកជន្លង!» ម្ដាយនាងសួរធ្វើឱ្យនាងដកអារម្មណ៍ចេញពីអារម្មណ៍រសាត់អណ្ដែតងាកមកសម្លឹងកូនកំលោះដែលកំពុងតែចុចស៊ីផ្លេបិទទ្វារឡាន។

ម្នាក់នេះទើបជាមង្គលចុះអ្នកដែលនាងឃើញអម្បាញ់មិញជាអ្នកណា? ចេន្ទីសួរខ្លួនឯង។

«កូនក្រមុំក៏ភ្ញាក់ឆាប់ដែរ! ល្អណាស់កូនប្រសាខ្ញុំ!» ម្ដាយមង្គលនិយាយផងងាកមកឆ្ងល់ដែរដែលម៉ោងមិនទាន់បីភ្លឺផងចាស់ៗផ្សេងៗដែលក្រោកមករោមរហង់ព្រោះភ្ញាក់ពីសម្រែករបស់កូនក្រមុំនេះ។

ចេន្ទីវិញ ដោយមិនរវល់ជាមួយអ្នកណាទាំងអស់ នាងឆាប់ឈានទៅរកមង្គល ស្រាប់តែត្រូវអ្នកម្ដាយទាញដៃឃាត់៖

«មកវិញ! កុំជួបគ្នាអីកូន! ជិតរៀបការគេត្រណម! ឡើងទៅបន្ទប់វិញសិនទៅ!»

នាងបង្ខំចិត្តមិនបានជួបប្រុសស្នេហ៍ហើយត្រូវម្ដាយហុចដៃ ឱ្យញាតិដឹកទៅសម្រាកបន្ទប់ខាងលើវិញ។

ទោះសង្ស័យនិងតាមដានជានិច្ចពីសភាពប្រតិកម្មប្លែកៗរបស់កូនស្រី តែថ្ងៃនោះគ្រប់យ៉ាងបន្តតាមកម្មវិធី ពិធីសិរីសួស្ដីយ៉ាងរៀបរយ។

រហូតម៉ោង១១ព្រឹក.....

«រឿងគឺដូច្នេះលោកប៉ូលិស មង្គលការត្រូវអាក់ខានដោយសារកំពុងតែដូរចិញ្ចៀនមិនទាន់បានសែនចងដៃផង ស្រាប់តែកូនកំលោះសន្លប់ស្ដូកស្ដឹងដោយមិនដឹងខ្លួននិងគ្មានមូលហេតុ»

ប៉ូលិសស្ដាប់ខាងកូនប្រុសនិយាយ រួចងាកទៅសម្លឹងគ្រប់យ៉ាងរប៉ាត់រប៉ាយក្នុងផ្ទះ។ ពិធីត្រូវបានបញ្ឈប់កណ្ដាលទីគួរឱ្យស្ដាយ។

ប៉ូលិសសង្កាត់ គឺពូបឿនបានសួរបន្ថែមឡើង៖

«ចុះហេតុអីបានជាមានកំណត់ហេតុថា កូនក្រមុំកើតស្រ្គេសស្រែកឡូឡាជាអំពើហិង្សាគប់បោកទៅលើក្រុមអ្នកភ្លេងបុរាណរហូតដល់មានពាក្យបណ្ដឹង?»

ម្ដាយចេន្នីនិងជន្លងឮសំណួរកាលណាក៏ងាកសម្លឹងទៅកូនក្រមុំដែលកំពុងអង្គុយជ្រប់មុខដូចជាខ្មោចចូល។

«ខ្ញុំមិនដឹងទេបងបឿន! កូនខ្ញុំមានរឿងប្លែកតាំងពីម៉ោងពីរបីភ្លឺ!»

ជន្លងជួយនិយាយបន្ថែម៖

«នៅសុខៗ កូនប្រុសខ្ញុំដួលសន្លប់មុខខ្មៅប៉ៃដូចជាគាំងបេះដូង ចំណែកឯខាងអ្នកភ្លេង នៅបន្តលេងភ្លេង ធ្វើឱ្យកូនក្រមុំច្រឡោតតោតតូង!»

បឿនងាកមកម្ដាយនាងសួរនាំខ្សឹបៗ៖

«អ្នកបង កូនចេន្នីកូនធ្លាប់មានជំងឺផ្លូវចិត្តអីទេ?»

«គ្មានទេ គួរតែសួរខាងកូនកំលោះ ហេតុអីបានជានៅសុខៗមកដួលសន្លប់!»

បឿនងក់ក្បាល៖

«បាទពួកខ្ញុំរង់ចាំរបាយការណ៍មន្ទីរពេទ្យ រហូតពេលនេះគ្មានអ្នកណាប្រាប់មកសោះ!»

ម្ដាយជេន្នីដូចជាខឹង គាត់រអ៊ូឡើងថា៖

«រហូតពេលនេះ ក៏មិនទាន់ដឹងថា កូនកំលោះក្រោកមកវិញបានពេលណា ហើយឈឺអ្វីឱ្យពិតប្រាកដ? ជាបានឬមិនបាននោះទេ!»

ម្ដាយកូនក្រមុំនិយាយដូច្នេះធ្វើឱ្យអ្នកជន្លងភ្ញាក់ព្រើតទៅជាខឹងឡូឡា៖

«រឿងអីព្យាបាលមិនបាន? កូនខ្ញុំហត់ពេក ក្រោកពីព្រឹកពេកហ្នឹងណា? អ្ហើយ ខ្ញុំថាឱ្យម៉ោងបួនភ្លឺចាំមក ស្រាប់តែគេទទូចថា ប្រពន្ធគេចង់ជួបគេ!»

«ប្រពន្ធណា?»

ម្ដាយកូនក្រមុំសួរហួសចិត្ត ស្រាប់តែម្ដាយកូនកំលោះខឹងណាស់ងាកទៅរាយការណ៍នឹងពូបឿន៖

«គឺចេន្ទីខ្លួនឯង បានទូរសព្ទមករកកូនប្រុសខ្ញុំ!»

«កុំនិយាយមួលបង្កាច់ កូនស្រីខ្ញុំនៅក្បែរខ្ញុំ គាត់គ្មានទូរសព្ទពីពេលណានោះទេ! ខ្ញុំដកទុកអស់ នៅនឹងខ្ញុំទាំងអស់»